# សូមគិតគូរប្រើអគ្គិសនីទាំងអស់គ្នា

## គេហដ្ឋានកាន់តែមានផាសុខភាព. មិនសូវចុះលុយ. បរិស្ថានបរិសុទ្ធ.

### ហេតុអ្វីប្រើអគ្គីសនី ?

- ជួយក្រុងឡុងប៊ិចឲ្យសម្រេចគោលដៅនៃផែនការសម្រប និងសកម្មភាពបរិស្ថាន ។ គេហដ្ឋានដែលប្រើអគ្គីសនីគ្រប់គ្នា កាត់បន្ថយផ្សែងពុលក្នុងបរិស្ថានបានពី ៤០-៥០% ជាងគេហដ្ឋានដែលប្រើហ្គាស ។[1]
- កាត់បន្ថយថ្លៃភ្លើង (មិនចាំបាច់ពឹងលើបំពង់បង្ហូរហ្គាស ) ។
- ខ្យល់អាកាសល្អក្នុងផ្ទះ ។ ផ្ទះដែលមានចង្ក្រានហ្គាស ជាទូទៅគឺប្រើលើសកម្រិតនៃសារជាតុនីត្រូហ្សែនអុកស៊ីត និងសារជាតុបំពុលឯទៀត ។[2]
- ផ្ទះបាយមានសុវត្ថិភាពជាង និងងាយស្រួលជូតសម្អាតជាង ។ ពេលបើកចង្ក្រានអគ្គីសនីក្តៅតែផ្ទាំង និងខ្ទះ ប៉ុន្តែផ្ទៃមុខនៃចង្ក្រានត្រង់កន្លែងផ្សេងទៀតនៅជុំវិញនោះ គឺមិនក្តៅទេ ។
- ជួយឲ្យអនុលោមតាមក្រុមថាមពល ដែលមានម៉ាស៊ីនកំដៅ និងម៉ាស៊ីនទឹកក្តៅ ។
- បើបងប្អូនមានគម្រោងដំឡើងបន្ទះសូឡា ប្រព័ន្ធអគ្គីសនីរបស់បងប្អូន អាចដំណើរការដោយថាមពលអគ្គីសនីដែលបានពីពន្លឺព្រះអាទិត្យលើដំបូលផ្ទះរបស់បងប្អូន ។ បើបងប្អូនដំឡើងអាគុយ បន្ទះសូឡារបស់បងប្អូនអាចរក្សាទុកអគ្គីសនី ទុកប្រើពេលដាច់ភ្លើង ។

1 “អគារលំនៅឋាន ដែលប្រើអគ្គីសនីនៅរដ្ឋកាលីហ្វ័រញ៉ា” E3, ខែ មេសា ឆ្នាំ ២០១៩

2 “ផលប៉ះពាល់នៃឧបករណ៍ប្រើហ្គាសតាមផ្ទះ ទៅលើគុណភាពខ្យល់ទាំងខាងក្នុងផ្ទះ និងក្រៅផ្ទះ

គុណភាពខ្យល់ និងសុខភាពសាធារណៈក្នុងរដ្ឋកាលីហ្វ័រញ៉ា” សាកលវិទ្យាល័យ LA មហាវិទ្យាល័យ Fielding ផ្នែកសុខភាពសាធារណៈ ខែ មេសា ឆ្នាំ ២០២០

### តើបានផលអ្វីខ្លះ ?

- កាត់បន្ថយថ្លៃចំណាយលើភ្លើង និងការចុះពិនិត្យទីតាំង មិនមានបំពង់ហ្គាស ឬនាឡិកា ។
- មិនសូវធ្វើចង្អៀតផ្ទះ ( កន្លែងចង្ក្រានអគ្គីសនីប្រើបានច្រើនមុខ )
- មានភាពបត់បែនច្រើនជាងមុន ក្នុងការរើកន្លែងដាក់ចង្ក្រានអគ្គីសនី ។
- ស័ក្តិសមសម្រាប់បន្ទប់ជួល នៅខាងក្រោយផ្ទះ ដែលសង់ជាប់ផ្ទះ និងសង់ដាច់ចេញពីផ្ទះ ។
- ងាយស្រួលពេលកែផ្ទះ ដើម្បីកាត់បន្ថយការបំពុលបរិស្ថាន ។

### តើធ្វើយ៉ាងដូចម្តេច ?

- បច្ចេកវិទ្យាកំដៅបានឈានដល់តំណាក់កាល នៃការផ្តល់កំដៅម៉ាស៊ីនត្រជាក់ ទឹកក្តៅ និងការសំងួតខោអាវដោយប្រើអគ្គីសនីដែលមានប្រសិទ្ធភាពជាងការប្រើហ្គាស ។
- កាត់បន្ថយគ្រោះថ្នាក់ ពីការប្រើប្រាស់គ្រឿងកំដៅពីដែក និងសុវត្ថិភាព និងការសន្សំសំចៃក្នុងការប្រើភ្លើង ។
- ជាងទូទៅ ជាងរថយន្ត និងជាងភ្លើងនឹងត្រូវដូរទៅឯកទេសខាងអគ្គីសនីទាំងអស់ ។
- ការទូទាត់ប្រាក់សងដើម្បីសម្របរឿងនេះ អាចមានពីរដ្ឋ និងជាតិ ។

LONGBEACH
COMMUNITY
DEVELOPMENT

THE AMERICAN INSTITUTE OF ARCHITECTS
AIA Long Beach/South Bay



## តើត្រូវចំណាយអ្វីខ្លះ?

- ករណីនៃប្រព័ន្ធហ្គាស និងភ្លើងអគ្គីសនីនៅតាមផ្ទះ៖ ទំហំ 2,100 square feet, ផ្ទះមួយជាន់មានបន្ទប់គេងបី សង់ប្រហែលក្នុងឆ្នាំ ១៩៥៨ ឡកំដៅដើរដោយហ្គាស និងម៉ាស៊ីនត្រជាក់, ប្រព័ន្ធទុយោនៅក្រោមដំបូល, ការស្រោបអ៊ីសូឡង់ និងបង្អួច, អត្រាថ្លៃអគ្គីសនី និងហ្គាស របស់រដ្ឋកាលីហ្វ័រញ៉ាភាគខាងត្បូង និងក្រុងឡុងប៊ីច គិតត្រឹមខែ កញ្ញា ឆ្នាំ ២០២២។
- ករណីនៃគេហដ្ឋានប្រើអគ្គីសនី៖ អត្រាតម្លៃតាមគម្រោង TOU-D-PRIME
- ថ្លៃទឹកភ្លើងនៅក្នុងតារាងខាងស្តាំ ដោយគិតចំណាយមួយឆ្នាំ។







## ហេតុអ្វីខ្ញុំទើបតែឮរឿងនេះ?

- រដ្ឋកាលីហ្វ័រញ៉ាប្តេជ្ញាធ្វើឲ្យគេហដ្ឋានទាំងអស់ប្រើអគ្គីសនី និងបន្តកម្មវិធីផ្តល់ប្រាក់លើកទឹកចិត្តឲ្យដូរបែបនេះ ជាដរាប។
- ទីក្រុងឡុងប៊ិចប្តេជ្ញាធ្វើឲ្យបានតាមគោលដៅនៃផែនការសម្រប និងសកម្មភាពបរិស្ថាន ដោយកាត់បន្ថយជាតិពុលពីអគារ និងតម្រូវឲ្យប្រើឥន្ធនៈហ្វូស៊ីលឲ្យកាន់តែតិចនៅតាមផ្ទះ។
- នៅពេលដែលឧស្សាហកម្មសំណង់ប្តូរបន្តិចម្តងៗ ឥឡូវយើងកាន់តែយល់ច្បាស់ អំពីផលប៉ះពាល់ដល់បរិស្ថាន និងសុខភាពយើងម្នាក់ៗ និងសុវត្ថិភាពផង ពីការប្រើប្រាស់ឥន្ធនៈហ្វូស៊ីលនៅតាមផ្ទះរបស់យើង។
- បច្ចេកវិទ្យាដែលប្រើអគ្គីសនីទាំងអស់ បានកែលម្អ និងឥឡូវមានប្រៀបខ្លាំងលើគ្រឿង និងយានយន្តដែលប្រើហ្គាស។

## ធនធានដែលមានប្រយោជន៍

សាលាក្រុងឡុងប៊ិច៖ longbeach.gov/lbcap
អគ្គីសនីរដ្ឋកាលីហ្វ័រញ៉ាភាគខាងត្បូង៖ sce.com
ផ្នែក The Switch is On: switchison.org

@LongBeachBuilds @AIALBSB

បើបងប្អូនចង់ស្នើសុំឯកសារនេះជាទម្រង់ផ្សេងនេះ ឬស្នើសុំការសម្របសម្រួលណាមួយសម្រាប់ជនពិការ សូមទាក់ទងនាយកដ្ឋានសេវាអភិវឌ្ឍន៍តាមរយៈ៖ longbeach.gov/lbcd and 562.570.3807។ យើងត្រូវការពេលយ៉ាងតិចបីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធានារកសេវាជូនទៅតាមសំណូមពរ។ ទោះជាយ៉ាងនេះក្តី យើងខ្ញុំនឹងព្យាយាមឆ្លើយតបតាមសំណូមពរដែលដាក់ក្នុងរយៈពេលខ្លីជាងនេះ។